# អនុត្តរិយៈ ធម្មជាតដ៏ប្រសើរ ៦

អនុត្តរិយៈ គឺធម្មជាតដ៏ប្រសើរ ឬធម្មជាតប្រសើរបំផុត នេះមាន ៦ យ៉ាងគឺ៖

| | |
|---|---|
| ១. ទស្សនានុត្តរិយំ | ទស្សនានុត្តរិយៈ ប្រសើរបំផុតដោយការឃើញ |
| ២. សវនានុត្តរិយំ | សវនានុត្តរិយៈ ប្រសើរបំផុតដោយការស្តាប់ |
| ៣. លាភានុត្តរិយំ | លាភានុត្តរិយៈ ប្រសើរបំផុតដោយការបាន |
| ៤. សិក្ខានុត្តរិយំ | សិក្ខានុត្តរិយៈ ប្រសើរបំផុតដោយការសិក្សា |
| ៥. បារិចរិយានុត្តរិយំ | បារិចរិយានុត្តរិយៈ ប្រសើរបំផុតខាងការបម្រើ |
| ៦. អនុស្សតានុត្តរិយំ | អនុស្សតានុត្តរិយៈ ប្រសើរបំផុតដោយការរលឹករឿយៗ |

(អនុត្តរិយសូត្រ បិដកលេខ ៤៦ ទំព័រ ១០ និងសង្គីតិសូត្រ បិដកលេខ ១៩ ទំព័រ ២០៧)

គប្បីជ្រាបសេចក្តីអធិប្បាយក្នុងអនុត្តរិយៈទាំងនេះដូចតទៅនេះ៖

បទថា អនុត្តរិយានិ សេចក្តីថា ( ការឃើញជាដើម ) ដែលវៀរចាកវត្ថុដទៃក្រៃលែងជាង ឈ្មោះថា អនុត្តរិយ ។ បទថា ទស្សនានុត្តរិយំ សេចក្តីថា ( ការឃើញព្រះពុទ្ធជាដើម ) ជាការឃើញដ៏ប្រសើរ ក្នុងការឃើញរូបទាំងឡាយក្នុងបទទាំងពួង ក៏មានន័យដូចគ្នា ។ អធិប្បាយថា ការឃើញដំរីកែវជាដើម មិនឈ្មោះថាជាទស្សនានុត្តរិយៈ ចំណែកការឃើញព្រះទសពលក្តី ព្រះភិក្ខុសង្ឃក្តី ដោយអំណាចសេចក្តីស្រឡាញ់ដ៏មាំ ការឃើញនិមិត្តណានីមួយ មានកសិណ និងអសុភនិមិត្តជាដើមក្តី របស់អ្នកមានសទ្ធាតាំងមាំហើយ ឈ្មោះថាទស្សនានុត្តរិយៈ។

ការស្តាប់គុណកថារបស់ក្សត្រជាដើម មិនឈ្មោះថាជាសវនានុត្តរិយៈ ចំណែកការស្តាប់គុណកថារបស់ព្រះរតនត្រ័យ ដោយអំណាចនៃសេចក្តីស្រឡាញ់ដ៏មាំក្តី ការស្តាប់ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកក្តី របស់អ្នកមានសទ្ធាតាំងមាំហើយ ឈ្មោះថាសវនានុត្តរិយៈ។

ការបានកែវមណីជាដើម មិនមែនជាលាភានុត្តរិយៈ ចំណែកការបានអរិយទ្រព្យ ៧ ឈ្មោះថាលាភានុត្តរិយៈ។

ការសិក្សាសិល្បៈទាក់ទងនឹងដំរីជាដើម មិនឈ្មោះថាជាសិក្ខានុត្តរិយៈ ចំណែកការបំពេញត្រៃសិក្ខាឈ្មោះថាសិក្ខានុត្តរិយៈ។

ការបម្រើក្សត្រជាដើម មិនឈ្មោះថា ជាបារិចរិយានុត្តរិយៈ ចំណែកការបម្រើព្រះរតនត្រ័យឈ្មោះថាបារិចរិយានុត្តរិយៈ។

ការរលឹកដល់គុណក្សត្រជាដើម មិនឈ្មោះថាជាអនុស្សតានុត្តរិយៈ ចំណែកការរលឹកដល់គុណព្រះរតនត្រ័យឈ្មោះថាអនុស្សតានុត្តរិយៈ។

អនុត្តរិយៈទាំង ៦ នេះ ព្រះមានព្រះភាគត្រាស់ទុក ទាំងលោកិយ ទាំងលោកុត្តរ ដោយប្រការដូចពណ៌នាមកនេះ ។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)